# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀង

## រវាង

## ក្រុមហ៊ុន ឌីឡាក់ស៍ អ៊ិនធើណេសិនណាល ឯ.ក

## នឹង

## តំណាងប្រតិភូបុគ្គលិកនឹងសហជីពមូលដ្ឋាន

## នៃរោងចក្រឌីឡាក់ស៍ អ៊ិនធើណេសិនណាល ឯ.ក

## ស្ដីពី

## ការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០វេលាម៉ោង៩ព្រឹកនៅក្នុងរោងចក្រ**ឌីឡាក់ស៍ អ៊ិនធើណេសិនណាល ឯ.ក** មានកិច្ចប្រជុំរវាងតំណាងប្រតិភូបុគ្គលិកនឹងសហជីពមូលដ្ឋានរបស់រោងចក្រ ។

នៅក្នុងសមយ័ប្រជុំនោះនាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៃកង្វះខាតវត្ថុធាតុដើម នឹងការរីករាលដាលនៃមេរោគកូវីណាដែលជាក្ដាចម្បងដែលធ្វើអោយទីផ្សារនៅអឺរ៉ុប សហរដ្ឋអាមេរិក ក៏ដូចជាទីផ្សាពិភពលោកមានការធ្លាក់ចុះនឹងមានការប៉ះពាល់ធ្ងន់ធ្ងដោយអ្នកបញ្ជាទិញបានផ្អាក នឹងលប់ចោលការបញ្ជាទិញ នឹងមិនអនុញ្ញាតិអោយមានការនាំទំនិញចេញជាដើម ។

ទាំងនេះជាមូលហេតុដែលនាំអោយក្រុមហ៊ុន **ឌីឡាក់ស៍ អ៊ិនធើណេសិនណាល ឯ.ក** ពុំមានលទ្ធភាពក្នុងការផ្ដល់ការងារជូនកម្មករនិយោជិតបាននៅក្នុងរយះពេលនេះ ។

ហេតុនេះក្រុមហ៊ុនសំរេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំងអស់រយះពេល ១៧ថ្ងៃដោយគិតចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០រហូតដល់ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០ ហើយនៅក្នុងរយះពេលនៃការព្យួរកិច្ចសន្យាការងារផងដែរកម្មករនិយោជិតបានឯកភាពទទួលយក ការផ្ដល់ជូនប្រាក់ឧបត្ថម្ភរបស់ក្រុមហ៊ុនទៅតាមសេចក្ដីជូនដំណឹងលេខ០៤៥/២០ ក.ប /ស.ណ.ន.ខ.ល របស់ក្រសួងការងារនឹងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

ក្រុមហ៊ុន ឌីឡាក់ស៍ អ៊ិនធើណេសិនណាល ឯ.ក D' LUXE INTERNATIONAL CO., LTD. KINGDOM OF CAMBODIA

បើកពីរដងក្នុងមួយខែក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារនេះ ។

លើសពីនេះទៀតយើងខ្ញុំបានយល់ព្រមផងដែរក្នុងការព្យួរកិច្ចសន្យាការងារបន្តប្រសិនបើក្រុមហ៊ុននៅមិនទាន់មានលទ្ធភាពស្វែងរកការងារសំរាប់កម្មករនិយោជិតបាននៅឡើយ ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១០នឹង៣០នាទីព្រឹកនៅថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងខាងមានភាពស្និទ្ធស្នាលនឹងដោយការយោគយល់គ្នាក្រោមស្មារតីទទួលនឹងសហការនៅក្នុងគ្រាដែលក្រុមហ៊ុនកំពង់ជួបប្រទះនូវការលំបាកនេះ ។

ថ្ងៃចន្ទ ៦រោច ខែចេត្រ ឆ្នាំជូតទោស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០

**តំណាងកម្មករនិយោជិត នឹងតំណាងសហជីព**

**នាយកក្រុមហ៊ុន**

D' LUXE INTERNATIONAL CO., LTD.
KINGDOM OF CAMBODIA

Zeki Ng